

# យុត្តិធម៌ផ្នែកច្បាប់ - យុទ្ធសាស្ត្រផ្តោតរបស់អាយស៊ីស៊ី

*យោងតាមការសិក្សាមួយដែលបានធ្វើឡើងដោយ អង្គការទស្សនៈពិភពលោកកម្ពុជា[1] បានរកឃើញថានៅក្នុងឆ្នាំ២០១៨ប្រហែលជា៤៩.៣% នៃចំនួនកុមារសរុបដែលមានអាយុចន្លោះពី១២ទៅ១៨ឆ្នាំ ត្រូវបានរងគ្រោះពីការរំលោភបំពានលើរាងកាយ។ នៅក្នុងការសិក្សាមួយនេះផងដែរ កុមារីម្នាក់អាយុ១៤ឆ្នាំដែលរស់នៅខេត្តកំពត និងត្រូវជាសិស្សថ្នាក់ទី៩ បាននិយាយថាអំពើហឹង្សាលើកុមារកើតមានជារៀងរាល់ថ្ងៃ នៅក្នុងសហគមន៍របស់នាង។ គួរឱ្យសោកស្តាយផងដែរ បញ្ហាស្រដៀងគ្នានេះបានកើតឡើងជារឿយៗនៅក្នុងតំបន់ផ្សេងៗទៀត នៅទូទាំងប្រទេសកម្ពុជា។ ការប្រារព្ធទិវា កុមារអន្តរជាតិ ឆ្នាំនេះគឺជាពេលវេលាមួយដ៏ល្អដើម្បីរំឭកខ្លួនយើងថា កុមារគឺជាគ្រឹះមួយដ៏សំខាន់សម្រាប់ការអភិវឌ្ឍសង្គម។ ដូចសុភាសិតខ្មែរមួយបាននិយាយថា "កុមារគឺជាទំពាំងស្នងឫស្សី"។ អង្គការអាយស៊ីស៊ី ជឿជាក់ថាកុមារគឺជាមនុស្សដែលមានតម្លៃ ហើយ សាកសមនឹងទទួលបានការការពារពីរាល់ទម្រង់ទាំងអស់នៃការកេងប្រវ័ញ្ច និងការរំលោភបំពាន។*

ចាប់ពីឆ្នាំ២០១២ រហូតមកដល់ចុងឆ្នាំ២០១៨ ការការពារកុមារគឺជាកត្តាសំខាន់បំផុតនៃគម្រោងសម្លេងកុមារ (វីអូធីស៊ី) របស់អង្គការអាយស៊ីស៊ី។ សមិទ្ធផលមួយចំនួន ដែលគម្រោងវីអូធីស៊ី ទទួលបានជោគជ័យ គឺសាកសមនឹងទទួលបានការផ្សព្វផ្សាយបង្ហាញជាសាធារណៈ។ សមិទ្ធផលទីមួយ គឺការពង្រឹងសិទ្ធិអំណាចទៅដល់អ្នកដឹកនាំសាសនា អ្នកភូមិ និងអាជ្ញាធរ បូករួមជាមួយនឹងការយល់ដឹងរបស់ពួកគាត់ អំពីសារៈសំខាន់នៃការការពារកុមារ ក៏ដូចជាសារៈសំខាន់នៃតួនាទី និងការទទួលខុសត្រូវរបស់ពួកគាត់ ក្នុងការការពារកុមារ។ សមិទ្ធផលមួយទៀត គឺការបង្កើតបាននូវ គណៈកម្មាធិការការពារកុមារ (គ.ក.ក) ចំនួន២១ ដែល គ.ក.ក មានតួនាទីក្នុងការនិយាយ និងធ្វើសកម្មភាពជំនួសឱ្យកុមារ ជាមួយនឹងភាគីពាក់ព័ន្ធ។ លើសពីនេះទៀត គម្រោងវីអូធីស៊ី បានទទួលជោគជ័យក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់កុមារនៅក្នុងក្រុមគ្រួសារ និងនៅក្នុងសហគមន៍ក្នុងខេត្តពោធិ៍សាត់ និងខេត្តតាកែវឱ្យបានកាន់តែប្រសើរឡើង។

ដើម្បីបន្តកសាងលើសមិទ្ធផល ដែលសម្រេចបានដោយគម្រោងវីអូធីស៊ី លើការការពារកុមារ និងការបំពេញសិទ្ធិកុមារឱ្យកាន់តែមានប្រសិទ្ធភាពនោះ គម្រោងថ្មីមួយដែលមានឈ្មោះថា គម្រោងសិទ្ធិកុមារ ត្រូវបានបង្កើតឡើង។ ចំណុចស្នូលនៃគម្រោងវីអូធីស៊ី គឺការប្រមូលផ្តុំសង្គមស៊ីវិល ដើម្បីបង្កឱ្យមានភាពសកម្មក្នុងការការពារកុមារ។ ប៉ុន្តែដើម្បីធានាបានថា ច្បាប់និងគោលនយោបាយមានវត្តមាន និងត្រូវបានអនុវត្តនោះ ក៏មានតម្រូវការ ក្នុងការកៀគរការចូលរួមពីស្ថាប័នរដ្ឋផងដែរ។ ដូច្នេះ គម្រោងសិទ្ធិកុមារ ថ្មីមួយនេះនឹងផ្តោតសំខាន់ទៅលើការស្វែងរកមតិគាំទ្រដើម្បីការពារកុមារ និង ការពារសិទ្ធិរបស់ពួកគេ នៅក្នុងរចនាសម្ព័ន្ធរាជរដ្ឋាភិបាលដែលមានស្រាប់។

រចនាសម្ព័ន្ធនេះរួមបញ្ចូលទាំង គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ (គ.ក.ស.ក) នៅថ្នាក់ខេត្តនិងស្រុក និងគណៈកម្មាធិការកិច្ចការនារីនិងកុមារ (គ.ក.ន.ក) នៅកម្រិតថ្នាក់ប្រតិបត្តិការ។ គណៈកម្មាការទាំងនេះត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស ហើយមានតួនាទីសំខាន់ក្នុងការរាយការណ៍ និងដំណើរការរឿងក្តីទាក់ទងនឹងស្ត្រីនិងកុមារ។ គោលបំណងស្នូលនៃ គម្រោងសិទ្ធិកុមារ គឺដើម្បីជួយនិងគាំទ្រស្ថាប័នរដ្ឋតាមរយៈ គ.ក.ស.ក និង គ.ក.ន.ក ដើម្បីបំពេញនូវកាតព្វកិច្ចរបស់ខ្លួនក្នុងការការពារកុមារ និងការអនុវត្តន៍ច្បាប់ និងសិទ្ធិកុមារ។ ម្យ៉ាងទៀត វាពិតជាចាំបាច់ណាស់ក្នុងការកែលម្អទំនាក់ទំនង អន្តរកម្ម និងកិច្ចសហការដែលមានស្រាប់រវាងរដ្ឋាភិបាលនិងសង្គមស៊ីវិលក្នុងគោលបំណងដើម្បីសម្រេចបាននូវលទ្ធផលប្រកបដោយចីរភាព និងនិរន្តភាពសម្រាប់ជាប្រយោជន៍ដល់ការការពារកុមារ និងសុខមាលភាពរបស់ពួកគេ។ លើសពីនេះទៀត គម្រោងសិទ្ធិកុមារ នឹងរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ក្នុងវង្វង់នៃកិច្ចការពារនិងអភិវឌ្ឍកុមារ។

គម្រោងសិទ្ធិកុមារ បានចាប់ផ្តើមឡើងនៅដើមឆ្នាំ២០១៩ និងកំពុងធ្វើប្រតិបត្តិការនៅខេត្តតាកែវ និងខេត្តស្វាយរៀង ជាខេត្តដែលអង្គការអាយស៊ីស៊ី មានទំនាក់ទំនងយ៉ាងជិតស្និតជាមួយដៃគូពាក់ព័ន្ធសំខាន់ៗនៅក្នុងស្ថាប័នរដ្ឋដែលទាក់ទងទៅនឹងការការពារកុមារ។ បុគ្គលិកជាច្រើន ដែលបានចាកចេញពី គម្រោងវីអូធីស៊ី បានផ្លាស់ប្តូរមកកាន់គម្រោងសិទ្ធិកុមារ ដែលទាំងអស់នេះបានសបញ្ជាក់ថាបទពិសោធន៍ ចំណេះដឹង ទំនាក់ទំនង។ល។ ត្រូវបានយកមកបញ្ចូលទៅក្នុងគម្រោងថ្មីនេះ។

អង្គការអាយស៊ីស៊ី ចង់ឃើញ តាមរយៈប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពនៅគ្រប់កម្រិតរបស់ គ.ក.ស.ក និង គ.ក.ន.ក កុមារនឹងទទួលបានការបំពេញដ៏គ្រប់ជ្រុងជ្រោយនូវសិទ្ធិនិងយុត្តិធម៌ដែលជម្រុញនាំឱ្យមានសុវត្ថិភាពផ្នែកកុមារភាព ការរៀនសូត្ររីកចម្រើន ការគោរព និងការឱ្យតម្លៃខ្លួនឯងកាន់តែប្រសើរឡើង។

កាលបរិច្ឆេទ៖ មិថុនា ២០១៩

[1] www.phnompenhpost.com/national/violence-against-kids-raised